# សូមស្វាគមន៍



## សូមស្វាគមន៍មកដល់ សៀវភៅណែនាំ ពីសិទ្ធិរបស់ជនអន្តោប្រវេសន៍ ភាពទទួលខុសត្រូវ និងជំនួយប្រយោជន៍ផ្សេងៗ នៅក្នុង ស្រុកសាន់តាក្លារ៉ា !

សេចក្តីប្រាថ្នានៃសៀវភៅនេះ គឺសំរាប់ជួយអ្នកអន្តោប្រវេសន៍ មកដល់ថ្មី និងមកយូរហើយ ឲ្យរៀន អំពី **សិទ្ធិ**របស់ខ្លួន ឲ្យយល់អំពី**ភាពទទួលខុសត្រូវ** របស់ខ្លួនជាប្រជាពលរដ្ឋម្នាក់។ បំណងយើងគឺ សំរាប់**លើកទឹកចិត្ត**គ្រួសារ ឲ្យចូលមកយកការបំរើ និងបន្តការផ្តល់ដំណឹងដល់ខ្លួនឯង អំពីស្ថាប័ន ច្បាប់ និង សិទ្ធិរបស់ខ្លួន។

សៀវភៅនេះ ចែកជា ៦ ផ្នែក :

- ការកសាងសហគម និង ចលនានៃប្រជាពលរដ្ឋ
- ថែទាំសុខភាព និង ការរស់នៅបានល្អប្រសើរ
- ការជួយឧបត្ថមគ្រួសារ
- អំពីរឿងច្បាប់
- អំពីការសិក្សារៀនសូត្រ
- អំពីរឿងការងារ

**ផ្នែកនិមួយៗត្រូវបែងចែកជាប្រធាន :**

ឧទាហរណ៍ ផ្នែកថែរក្សាសុខភាពមាន ៣ប្រធាន :
-ការថែរក្សាសុខភាពមនុស្ស ម្នាក់ៗ និង ក្រុមគ្រួសារ
-ម្ហូបអាហារ និង ជីវជាតិ និង
-ការពិបាកចិត្ត និង ការថែរក្សាសុខភាពផ្លូវចិត្ត។

ផ្នែកនិមួយៗមានផ្តល់ពត៌មាន សំរាប់ទាក់ទងជាមួយ ភ្នាក់ងារ និងប្រព័ន្ធសហគមន៍ ដែលផ្តល់ការបំរើ និងកម្មវិធី សំរាប់ជួយអ្នកអន្តោប្រវេសន៍និងគ្រួសារខ្លួន។

ដើម្បីដំណឹងបន្ថែមសូមមើល www.immigrantinfo.org

## ពាក្យប្រើនៅក្នុងសៀវភៅនេះ

សៀវភៅនេះសសេរសំរាប់ ជួយអ្នកអន្តោប្រវេសន៍ទាំងអស់មិនថាអ្នកនោះ មានសភាពអន្តោប្រវេសន៍យ៉ាងណាក៏ដោយ ក៏ប៉ុន្តែផលប្រយោជន៍ខ្លះ ត្រូវតែចាំបាច់ជននោះ ជាអ្នកអន្តោប្រវេសន៍ពេញលក្ខណះ ទើបទទួលផលប្រយោជន៍បាន។

**អ្នកអន្តោប្រវេសន៍ពេញលក្ខណ: គឺ ជាមនុស្សដែល :**
**អ្នកសញ្ជាតិអាមេរិកាំង** – ជាមនុស្សដែលកើត ក្នុងស្រុកសហរដ្ឋអាមេរិក/ឬក៏ស្រុកក្រៅ ដែលមានឪពុកម្តាយជាជនជាតិអាមេរិក មនុស្សដែលចូលសញ្ជាតិ និងកូនក្មេងដែលមាន អាយុក្រោម១៨ឆ្នាំ ដែលមានឪពុកម្តាយចូលសញ្ជាតិ។

**អ្នកមានច្បាប់រស់នៅជាអចិន្ត្រៃ** -អ្នកដែលទទួលវីសាជាជន អន្តោប្រវេសន៍ ហើយបានសិទ្ធរស់នៅស្រុកអាមេរិក (កាតបៃតង)។

**ជនភាសខ្លួន** – អ្នកគ្មានសញ្ជាតិ ដែលពេលនៅក្រៅស្រុក សហរដ្ឋអាមេរិក និងនៅក្រៅស្រុករបស់ខ្លួនបានទទួលច្បាប់ សញ្ជាតិ ឲ្យរស់នៅសហរដ្ឋអាមេរិក ដោយសារភ័យនឹងការធ្វើបាប នៅពេលត្រឡប់ទៅក្នុងស្រុកខ្លួនវិញ។

**អាស៊ីលី** – អ្នកគ្មានសញ្ជាតិ ដែលពេលនៅក្នុងស្រុកសហរដ្ឋអាមេរិក បានទទួលច្បាប់សញ្ជាតិឲ្យរស់នៅសហរដ្ឋអាមេរិក ដោយសារភ័យនឹងការធ្វើបាបនៅក្នុងស្រុកខ្លួន។

**អ្នកដែលត្រូវទទួលការបញ្ឈប់ ឬដកហូតការបញ្ជូនទៅស្រុកវិញ** – អ្នកគ្មានសញ្ជាតិ តែបានទទួលច្បាប់ឲ្យនៅស្រុកសហរដ្ឋអាមេរិក ដោយសារជីវិតនិងសេរីភាពគេ ត្រូវការកំរាមកំហែងក្នុងពេលដែលត្រឡប់ទៅស្រុកវិញ។ សភាពនេះស្រដៀងគ្នា តែដាច់ពីអាស៊ីឡឺម។

**អ្នកចូលពីស្រុកគុយបាន / ហៃតែន** – សញ្ជាតិគុយបា / ហៃទី បានឲ្យច្បាប់ អនុញ្ញាត្តិចូលទៅក្នុង សហរដ្ឋអាមេរិក ដោយសារយល់ច្បាប់ថា គេអាចរស់ក្នុងស្រុកអាមេរិក ជាប់រហូត ឬបណ្តោះអាសន្ន។ ជននិមួយៗ អាចបានទទួលជំនួយជនភាសខ្លួន និងផលប្រយោជន៍សាធារណ:ជាច្រើនទៀត។

**អាមេរ៉ាស៊ីអៀន** -អ្នកដែលបានទទួលច្បាប់រស់នៅ ជាភាពអចិន្ត្រៃក្រោមច្បាប់ពិសេស សំរាប់មនុស្សកើតនៅស្រុកវៀតណាម។ អ្នកដែលបាន សភាពនេះត្រូវតែកើតនៅស្រុកវៀតណាម ក្រោយខែ១ ថ្ងៃ១ឆ្នាំ១៩៦១ និងមុន ខែ១ថ្ងៃ១ឆ្នាំ១៩៧៦ ជាមួយនឹង ឪពុកជាតិអាមេរិកកាំង ឬក៏ជាប្រពន្ធកូននៃអ្នកដែលមានរៀបរាប់ខាងលើនេះ។





តើអ្នកចង់រកថ្នាក់រៀន ជាភាសាអង់គ្លេសឬ? សូមរក កន្លែងនិងតារាងពេលវេលា នៃថ្នាក់រៀន ESL ដែលមានថ្នាក់រាប់រយ ផ្តល់ឲ្យនៅស្រុកសាន់តាក្លារ៉ា ដោយរកមើលតាម អិនធើណិត www.immigrantinfo.org ។

# សូមស្វាគមន៍



